# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៩...សសរ

## សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការ

ដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូល អនុតំបន់វិសាលភាពទន្លេមេគង្គ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ប្រការ១:** បង្កើតគណៈកម្មការដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូល នៃអនុតំបន់វិសាលភាពទន្លេមេគង្គ (Greater Mekong Sub-region - GMS) ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ហោ ណាំហុង** | ទេសរដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម **ឆាយ ថន** | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៤-ឯកឧត្តម **ឃី តាំងលីម** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥-ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

www.pheakdeylaw.com

**ប្រការ២:** គណៈកម្មការនេះមានភារកិច្ចរៀបចំ កិច្ចប្រជុំកំពូលអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) នៅភ្នំពេញ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ កិច្ចប្រជុំនេះ នឹងត្រូវធ្វើមួយថ្ងៃមុន កិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ ២០០២ នៅភ្នំពេញ ។

**ប្រការ៣:** គណៈកម្មការនេះ នឹងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅភ្នំពេញ ដើម្បីរៀបចំកិច្ចប្រជុំកំពូលនេះ អោយបានជោគជ័យ ។

**ប្រការ៤:** ដើម្បីរៀបចំការងារអោយមានភាពប្រមូលផ្តុំចាប់ពីពេលនេះទៅ ឯកឧត្តម *ចម ប្រសិទ្ធ* អនុប្រធាន និង ឯកឧត្តម *អូន ព័ន្ធមុនីរ័ត្ន* សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមរាល់កិច្ចប្រជុំដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍អាងទន្លេមេគង្គ គឺអនុតំបន់វិសាលភាពទន្លេមេគង្គ (GMS) និង កិច្ចសហប្រតិបត្តិការអាស៊ាន ដើម្បីអភិវឌ្ឍន៍អាងទន្លេមេគង្គ (AMBDC) ។

**ប្រការ៥:** គណៈកម្មការនេះ នឹងបង្កើតលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្នុងករណីចាំបាច់ ហើយមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេស មកពីបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធ អោយចូលរួមប្រជុំ ឬ ជួយបំពេញការងារ ក្នុងឋានៈជាជំនួយការខាងផ្នែកបច្ចេកទេស ។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com